## ១. បច្ចុប្បន្នភាពសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ជាសមាគមអព្យាក្រឹត មិនស្វែងរកប្រាក់កម្រៃជាឯកជនមិនប្រកាន់ពូជសាសន៍ មិនប្រកាន់សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ មិនធ្វើជាឧបករណ៍របស់គណបក្សនយោបាយ ក្នុងនោះមិនផ្តល់ជាសម្ភារ ហិរញ្ញវត្ថុ ធនធានមនុស្ស ដើម្បីគាំទ្រគណបក្សនយោបាយ ឬបេក្ខជន ឬអ្នកគាំទ្រណាមួយឡើយ។ សមាគមបម្រើឱ្យផលប្រយោជន៍សមាជិក និងផលប្រយោជន៍សាធារណៈតាមលទ្ធភាពដែលសមាគមអាចចូលរួមបាន។

សមាគមបង្កើតឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដោយក្រុមអ្នកផ្គត់ផ្គង់ទឹកស្អាតឯកជនមួយក្រុមមានគ្នាប្រមាណជា ២០នាក់ ក្រោមជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ របស់គម្រោង អេម អេស អេម អ៊ី កម្ពុជា (MSME) ឧបត្ថម្ភដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងបានចុះបញ្ជីសមាគមជាផ្លូវការនៅក្រសួងមហាផ្ទៃ តាមសេចក្តីជូនដំណឹងលេខៈ ១០៧៧ សជណ របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១២។ ក្រសួងមហាផ្ទៃចេញសេចក្តីប្រកាសលេខៈ ២៩០១ ប្រក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២១ សម្រេចចុះឈ្មោះសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គល នៅក្រសួងមហាផ្ទៃ ដោយមានអាសយដ្ឋាននៃទីស្នាក់ការកណ្តាលស្ថិតនៅអគារ F ជាន់ទី២ បន្ទប់លេខ ២៦៩ នៃមជ្ឈមណ្ឌលភ្នំពេញ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

សមាគមបង្កើតឡើងក្នុងគោលបំណងប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនប្រកាន់និន្នាការនយោបាយអ្វីឡើយ។

គិតត្រឹមបំណាច់ត្រីមាសទី២ ឆ្នាំ២០២៣ សមាគមមានសមាជិកសរុបចំនួន ៣៣០ស្ថានីយ / ក្រុមហ៊ុនដែលបាននឹងកំពុងប្រតិបត្តិការនៅក្នុង ២៣រាជធានី/ខេត្ត/ក្រុង នៃព្រះរាជាណាចក្រកម្ពុជា ក្នុងនោះមានសមាជិកអាជីពចំនួន ២៩៦ស្ថានីយ និងសមាជិកគាំទ្រចំនួន ៣៤ក្រុមហ៊ុន។

## ២ .ក្រុមប្រឹក្សាភិបាល

### ២.១ កិច្ចប្រជុំប្រចាំត្រីមាស

ថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២៣ សមាគមបានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាភិបាលសម្រាប់ត្រីមាសទី១ ឆ្នាំ២០២៣ វេលាម៉ោង ១.៣០រសៀល នៅការិយាល័យរបស់សមាគម និងមានការសម្រេចដូចខាងក្រោមៈ

១. បានអនុម័តទៅលើកំណត់ហេតុកិច្ចប្រជុំវិសាមញ្ញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៣

២. សម្រេចក្នុងការរៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់គ្រប់គ្រងទឹកស្អាត នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ ២០២៣

៣. សម្រេចអំពីសមាសភាពអ្នកចូលរួមពិព័រណ៌ទឹកស្អាតនៅប្រទេសអូស្ត្រាលី ថ្ងៃទី០៨-១២ ខែឧសភា ឆ្នាំ២០២៣ (Ozwater'23 in Sydney & Study in Melbourne)



*រូបភាពទី ១៖ កិច្ចប្រជុំក្រុមប្រឹក្សាភិបាលប្រចាំត្រីមាសទី ២ នៅការិយាល័យសមាគម*

## ២.២. កិច្ចប្រជុំវិសាមញ្ញ

ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣ ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំសមាគម បានប្រជុំជាមួយតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដែលតំណាងដោយ **លោក Rene Van Doorn** និង លោក ម៉មដេត។ កិច្ចប្រជុំបានពិភាក្សាពីគម្រោងរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលើការផ្គត់ផ្គង់ទឹកស្អាត ដែលក្នុងនោះមានគម្រោង២សំខាន់ៗ គឺទី១). គម្រោងកម្មវិធីទន្លេសាប២ របស់ក្រសួងសាធារណៈការ ដែលបានអនុវត្តនៅខេត្តចំនួន ២គឺ ខេត្តកំពង់ធំ និងខេត្តបាត់ដំបង ទី២). គម្រោងកម្មវិធីធ្វើឱ្យប្រសើរឡើងនូវទឹកស្អាត និងអនាម័យប្រកបដោយនិរន្តភាព របស់ក្រសួងអភិវឌ្ឍន៍ជនបទ អនុវត្តនៅនៅខេត្តចំនួន ៩ រួមមាន៖ ខេត្តកំពង់ស្ពឺ ព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ ប៉ៃលិន បាត់ដំបង កំពត ក្រចេះ និងស្ទឹងត្រែង។



*រូបភាពទី ២៖ ប្រជុំជាមួយតំណាងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅការិយាល័យសមាគម*

សម្រាប់គម្រោងនេះត្រូវធ្វើការសិក្សាសមិទ្ធិលទ្ធភាពចាប់ពីខែកញ្ញា ឆ្នាំ២០២២ រហូតដល់ខែតុលា ឆ្នាំ ២០២៣។

ក្រោយពីការបង្ហាញក្តីកង្វល់របស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ទាក់ទងទៅនឹងទឹកសហគមន៍ដែលបានអនុវត្តគម្រោងនៅក្នុងតំបន់អាជ្ញាបណ្ណរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ដែលបានរារាំងដល់ការពន្លឿនការទទួលទឹកស្អាតដល់ប្រជាពលរដ្ឋនោះមក។

- **លោក Rene** បានបញ្ជាក់ថា លោកនឹងពាំនាំយកនូវបញ្ហា ក្តីកង្វល់ និងលទ្ធផលនៃកិច្ចប្រជុំនេះទៅពិភាក្សាគ្នាបន្ថែមទៀតដែលទាក់ទងទៅនឹងការងារមួយចំនួនដូចខាងក្រោម៖
  - មិនអនុញ្ញាតឱ្យមានការសិក្សាសមិទ្ធិលទ្ធភាពនៅក្នុងតំបន់ដែលមានអាជ្ញាបណ្ណផ្គត់ផ្គង់ទឹកស្អាតឯកជន។
  - ក្រុមការងារ ABD ដែលបានធ្វើការសិក្សាសមិទ្ធិលទ្ធភាពរួចហើយ បើតំបន់នោះមានអាជ្ញាបណ្ណត្រូវបង្វែរចេញ ហើយនឹងពិចារណាយកថវិកានេះទៅជួយគាំទ្រដល់ប្រតិបត្តិករធ្វើការទៅលើ វិស័យទឹកស្អាតនៅក្នុងតំបន់នោះវិញ។
  - របាយការណ៍នៃការសិក្សាសមិទ្ធិលទ្ធភាពនឹងត្រូវបញ្ចប់នៅខែកក្កដា ឆ្នាំ២០២៣ ហើយបើមិនមានការរាំងស្ទះប្រការណាមួយទេនោះ នៅខែសីហា ឆ្នាំ២០២៣ យើងនឹងត្រូវជួបប្រជុំគ្នាម្តងទៀត ហើយ**លោក Rene** នឹងទំនាក់ទំនងមក **លោក លឹម មិញ** ដើម្បីណាត់ពេលដែលនឹងត្រូវជួបប្រជុំគ្នាជាថ្មីម្តងទៀត។

## ៣. ការងារស្នូលសមាគម

### ៣.១. ការសម្របសម្រួលសមាជិក

នៅក្នុងត្រីមាសទី២ នេះសមាគមបានសម្របសម្រួលដោះស្រាយបញ្ហាសមាជិកចំនួន ១ស្ថានីយ គឺស្ថានីយផ្គត់ផ្គង់ទឹកស្អាតសាយហុង ដែលមានបញ្ហាជាមួយទឹកសហគមន៍កសិកម្មស្ត្រីដើម្បីជីវិតថ្លៃថ្នូរ ឃុំតាំងស្យា ក្នុងការផ្គត់ផ្គង់ទឹក និងរាយបណ្តាញក្នុងដែនអាជ្ញាបណ្ណរបស់ **លោក សាយ ហុង**។

**<u>លទ្ធផល និងសេចក្តីសម្រេច</u>**

ក្រោមកិច្ចសម្របសម្រួលអង្គប្រជុំដោយ ឯកឧត្តម **ស្រ៊ុន ស្រ៊ន់** អភិបាលរងខេត្តកំពង់ស្ពឺ ដែលមានការចូលរួមពីមន្ទីរឧស្សាហកម្ម (មន្ទីរឧវបនកំពង់ស្ពឺ) មន្ទីរអភិវឌ្ឍន៍ជនបទ ក្រុមប្រឹក្សាភិបាលសមាគម បុគ្គលិកសមាគម និងភាគីទាំងពីរ។ **ឯកឧត្តម** បានស្នើឱ្យមានការដោះស្រាយបែបយោគយល់គ្នា និងឈ្នះឈ្នះទាំងអស់គ្នា។ ក្រោយពីការពិភាក្សាគ្នាមក ភាគីទាំងពីរបានព្រមព្រៀងដូចក្រោម៖

១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត **សាយ ហុង** យល់ព្រមអនុញ្ញាតឱ្យទឹកសហគមន៍អាចបន្តផ្គត់ផ្គង់ទឹកជូនប្រជាពលរដ្ឋ ត្រួតលើតំបន់អាជ្ញាបណ្ណរបស់ខ្លួនចំនួន ៤ភូមិរួមមាន៖ ភូមិជ្រៃ ភូមិកណ្តាលកោង ភូមិតាំងស្យា និងភូមិត្នោតព្រែក។ ប៉ុន្តែសម្រាប់ភូមិឈើនាងខ្ពស់ ស្ថានីយមិនអនុញ្ញាតឱ្យទឹកសហគមន៍រាយបណ្តាញបំពង់ទឹកចូលដើម្បីចែកចាយទឹកឡើយ។

២. ស្ថានីយផ្គត់ផ្គង់ទឹកស្អាត **សាយ ហុង** បានបញ្ជាក់ថា នៅថ្ងៃអនាគតប្រសិនបើខាងសហគមន៍ក្បៀយធន ខាងស្ថានីយនឹងមិនទទួលយកការចរចាណាមួយដើម្បីទិញបណ្តាញបំពង់ទុយោរបស់សហគមន៍ដែលបានវាយបណ្តាញនោះ។

៣. សហគមន៍កសិកម្មស្ត្រីដើម្បីសេចក្តីថ្លៃថ្នូរ ឃុំតាំងស្យា យល់ព្រមទទួលយកការផ្គត់ផ្គង់ទឹកសម្រាប់ ៤ភូមិខាងលើ និងមិនបន្តពង្រីកបណ្តាញបំពង់ទឹកចូលទៅកាន់ភូមិឈើនាងខ្ពស់នោះទេ។

៤. សម្រាប់ភូមិទាំងបួនខាងលើ ភាគីទាំងពីរបានព្រមព្រៀមគ្នាថា ប្រជាពលរដ្ឋមានសិទ្ធិជ្រើសរើសតភ្ជាប់ទឹកស្អាតដើម្បីប្រើប្រាស់ពីភាគីណាមួយក៏បានតាមការស្ម័គ្រចិត្តរបស់ពួកគាត់ (អាចភ្ជាប់ទឹកជាមួយស្ថានីយផ្គត់ផ្គង់ទឹកស្អាត សាយ ហុង ឬទឹករបស់សហគមន៍កសិកម្មស្ត្រីដើម្បីសេចក្តីថ្លៃថ្នូរ ឃុំតាំងស្យា)។

៥. ទឹករបស់សហគមន៍កសិកម្មស្ត្រីដើម្បីសេចក្តីថ្លៃថ្នូរ ឃុំតាំងស្យា ត្រូវតែអនុលោមតាមលក្ខខណ្ឌ ៤យ៉ាងនៃទឹកស្អាត រួមមាន៖ គុណភាព សុវត្ថិភាព និរន្តរភាព និងថ្លៃសមរម្យ។

៦. ការតេស្ត និងត្រួតពិនិត្យគុណភាពទឹករបស់ទឹកសហគមន៍ជាបន្ទុករបស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកំពង់ស្ពឺ។

៧. មន្ត្រីរដ្ឋបាលខេត្តកំពង់ស្ពឺនឹងរៀបចំជាកំណត់ហេតុ សម្រាប់អង្គប្រជុំ ព្រមទាំងរៀបចំកិច្ចសន្យាជូនទៅ ភាគីស្ថានីយផ្គត់ផ្គង់ទឹកស្អាត សាយ ហុង និងសហគមន៍កសិកម្មស្ត្រីដើម្បីសេចក្តីថ្លៃថ្នូរ ឃុំតាំងស្យា ដើម្បីចុះកិច្ចព្រមព្រៀងបញ្ចប់ករណីទំនាស់នេះដោយសន្តិវិធី។




*រូបភាពទី ៖៣ កិច្ចប្រជុំដោះស្រាយទំនាស់រវាងទឹកស្អាត សាយហុង និងទឹកសហគមន៍កសិកម្មស្ត្រីដើម្បីជីវិតថ្លៃថ្នូរ ឃុំតាំងស្យា*



*រូបភាពទី ៖៤ កិច្ចប្រជុំដោះស្រាយទំនាស់រវាងទឹកស្អាត សាយហុង និងទឹកសហគមន៍កសិកម្មស្រ្តីដើម្បីជីវិតថ្លៃថ្នូរ ឃុំតាំងស្យា*

## ៣.២ ជំនួយបច្ចេកទេសដល់សមាជិក

ក្នុងត្រីមាសនេះ សមាគមបានធ្វើតេស្តគុណភាពទឹកស្អាតលើប៉ារ៉ាម៉ែត្រប្រចាំថ្ងៃទាំង៥ និងធ្វើជ្យាតេស្ត ទឹកឆៅ ជូនស្ថានីយទឹកស្អាតភ្នំលៀប។ ជាលទ្ធផល ដោយស្ថានីយទឹកស្អាតភ្នំលៀបបច្ចុប្បន្នប្រើប្រាស់សាច់ជូរក្នុងការសម្អាតទឹក ដូច្នេះត្រូវចាក់បញ្ចូលសារធាតុគីមីគឺកំបោរ ដើម្បីរក្សាប៉េហាស (pH) ឱ្យត្រូវតាមស្តង់ដា។ ម្យ៉ាងទៀត ស្ថានីយនេះគួរប្រើប្រាស់ផេក(PAC)ជំនួសសាច់ជូរ ដែលធ្វើឱ្យចំណេញប្រាក់។

## ៣.៣ ការធ្វើបច្ចុប្បន្នភាពរបស់សមាជិក

ក្នុងត្រីមាសនេះ បុគ្គលិកសមាគមបានប្រមូលព័ត៌មានបច្ចុប្បន្នភាពរបស់សមាជិករួមមាន៖

១. ប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្ម (អាជ្ញាបណ្ណ ២០ឆ្នាំ) ដែលទទួលបាន និងកំពុងស្នើសុំ

២. ចំនួនតំណអតិថិជនរបស់សមាជិកដែលជាប្រតិបត្តិករ

ព័ត៌មានបច្ចុប្បន្នភាពនេះនឹងត្រូវរៀបចំជូនទៅក្រសួង ឧវបន ដើម្បីជំរុញការចេញអាជ្ញាបណ្ណ ២០ឆ្នាំ ជូនដល់សមាជិកសមាគម។

## ៣.៤ ការចូលជាសមាជិកថ្មីរបស់សមាគម

ក្នុងត្រីមាសនេះ សមាគមបានទទួលសមាជិកថ្មីចំនួន ០៧ស្ថានីយ/ក្រុមហ៊ុន ដូចខាងក្រោម៖

១. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតសាមគ្គី ដែលមានទៅតាំងនៅភូមិព្រែកក្រាញ់ ឃុំសាមគ្គី ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

២. ស្ថានីយផ្គត់ផ្គង់ពាមរក៍ ដែលមានទីតាំងនៅភូមិពាមកោះ ឃុំពាមរក៍ ស្រុកពាមរក៍ ខេត្តព្រៃវែង

៣. ក្រុមហ៊ុន សសរស្តម្ភ វ៉ាជើរ សឹបផ្លាយ ទីតាំងនៅភូមិគោកស្រម៉ ឃុំល្វា ស្រុកពួក ខេត្តសៀមរាប

៤. ស្ថានីយផ្គត់ផ្គង់ទឹកស្អាតចុងដូង ដែលមានទីតាំងនៅភូមិកំប៉ើយ ឃុំចុងដូង ស្រុកបាយរាំណ៍ ខេត្តកំពង់ធំ

៥. ក្រុមហ៊ុន ថេបអេហ៊ិប ឯ.ក ដែលមានទីតាំងនៅភូមិតាសល់ ឃុំគោកបល្ល័ង ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ

៦. ក្រុមហ៊ុន ជីងតុង វ៉េហ៊ី ផាយធ៌ (ខេមបូឌា) ដែលមានទីតាំងនៅភូមិអញ្ចាញ ឃុំទំនប់ ស្រុកពញាឮ ខេត្តកណ្ដាល

៧. ក្រុមហ៊ុនលេសសូ (ខេមបូឌា) ត្រេឌីង ឯ.ក ដែលមានទីតាំងនៅភូមិត្រពាំងជូន ឃុំធក់ឈើនាង ស្រុកអង្គស្នួល ខេត្តកណ្ដាល។

## ៤. ការខារគម្រោង

### ៤.១. ការកែលម្អលទ្ធភាពទទួលបានហិរញ្ញប្បទានរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅកម្ពុជា ដើម្បីពង្រីកវិសាលភាពផ្គត់ផ្គង់ទឹកស្អាត

#### ៤.១.១. វគ្គបណ្ដុះបណ្ដាល

នៅក្នុងត្រីមាសទី២ សមាគម បានរៀបចំវគ្គបណ្ដុះបណ្ដាលស្ដីពី«ការធ្វើទីផ្សារសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» នៅសណ្ឋាគារ ពូលូវ៉ៃ រាជធានីភ្នំពេញ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣។ ក្រោយបញ្ចប់វគ្គបណ្ដុះបណ្ដាលសិក្ខាកាមអាចមានលទ្ធភាព៖

១. រៀបរាប់អំពីវិធីសាស្ត្រទីផ្សារក្នុងការជំរុញកំណើនតំណ

២. អាចកំណត់ឧបករណ៍/បច្ចេកទេសទីផ្សារក្នុងការជម្រុញឱ្យមានកំណើនតំណ

៣. ធ្វើឱ្យមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋនៅក្នុងដំណើរការផ្គត់ផ្គង់ទឹកស្អាត នឹងបង្កើតអាជីវកម្មមួយប្រកបដោយជោគជ័យ និងមានទំនាក់ទំនងល្អជាមួយអតិថិជន។



*រូបភាពទី៖ ៥ វគ្គបណ្ដុះបណ្ដាលស្ដីពី«ការធ្វើទីផ្សារសម្រាប់អាជីវកម្មផ្គត់ផ្គង់ទឹកស្អាត» នៅសណ្ឋាគារ ពូលូវ៉ៃ រាជធានីភ្នំពេញ*

វគ្គបណ្ដុះបណ្ដាលនេះមានអ្នកចូលរួមសរុបចំនួន ៣១នាក់(ស្រី១២នាក់)ដែលមានការអញ្ជើញមកពីតំណាងអគ្គនាយកដ្ឋានទឹកស្អាតនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តំណាងអង្គការ Water.org តំណាងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល អូ អិល ស៊ី បុគ្គលិកសមាគម និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ចំនួន ១៨ស្ថានីយ។

### ៤.១.២. ការពង្រឹងសមត្ថភាពប្រតិបត្តិករលើប្រព័ន្ធគណនេយ្យ

ក្រុមការងារគម្រោងបានធ្វើការប្រជុំតាមអនឡាញជាមួយប្រតិបត្តិករដើម្បីពិភាក្សាអំពី«**តម្រូវការទិន្នន័យសម្រាប់បើកទិន្នន័យដើមគ្រា**» នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៣។ កិច្ចប្រជុំនេះបានពិភាក្សាអំពីតម្រូវការឯកសារ និងទិន្នន័យដែលត្រូវការដើម្បីប្រមូលសម្រាប់ការបើកសមតុល្យ។ ជាលទ្ធផលមានអ្នកចូលរួមសរុបចំនួន ៣៨នាក់ មកពីស្ថានីយទឹកស្អាត ២៨ស្ថានីយ បុគ្គលិកក្រុមហ៊ុនអ៊ីផោរ៉េ ស៊ីស៊ីអិល និងបុគ្គលិកសមាគម។




*រូបភាពទី៖ ៦ សិក្ខាកាមចូលរួមនៅក្នុងកិច្ចប្រជុំតាមអនឡាញស្តីពី«តម្រូវការទិន្នន័យសម្រាប់បើកទិន្នន័យដើមគ្រា»*

### ៤.១.៣. ការផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត

ក្រោមកិច្ចសហការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សមាគមបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត តាមរយៈជំនួយឧបត្ថម្ភពីអង្គការ Water.org។ សិក្ខាសាលានេះមានការចូលរួមជាអធិបតីភាព **ឯកឧត្តម អ៊ុំ សុថា** រដ្ឋលេខាធិការក្រសួងឧវបន និងជាតំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧវបន**។ សិក្ខាសាលាផ្សព្វផ្សាយនេះរៀបចំឡើងក្នុងគោលបំណងឱ្យភាគីពាក់ព័ន្ធទាំងអស់យល់កាន់តែច្បាស់អំពីខ្លឹមសារនៃច្បាប់ថ្មី ជាពិសេសប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន បានយល់ច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនក្នុងការផ្តល់សេវាកម្មផ្គត់ផ្គង់ទឹកស្អាត។ ចំនួនអ្នកចូលរួមសរុបមាន ៣១៦នាក់ (ស្រី៨៣នាក់) អញ្ជើញមកពីក្រសួង ឧវបន តំណាងក្រសួងអភិវឌ្ឍន៍ជនបទ តំណាងដៃគូអភិវឌ្ឍន៍ អង្គការ Water.org សមាជិកសមាគមជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងក្រុមហ៊ុន។




*រូបភាពទីៈ ៧ សិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងទឹកស្អាត នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ*

### ៤.១.៤. កិច្ចប្រជុំជាមួយស្ថាប័នហិរញ្ញវត្ថុ

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា បានសម្របសម្រួលអញ្ជើញប្រតិបត្តិករចំនួន ១០ស្ថានីយ ចូលរួមក្នុងសិក្ខាសាលាស្តីអំពី«ការចាប់ផ្តើមកម្មវិធីឥណទានទឹកស្អាត» នៅថ្ងៃពុធ ទី០៧ ខែមិថុនា ឆ្នាំ ២០២៣ នាសណ្ឋាគារភ្នំពេញ ដែលសហការរៀបចំដោយ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងអង្គការ Water.org។ សិក្ខាសាលានេះ ធ្វើឡើងក្នុងគោលបំណង ផ្តល់ជាវេទិកាសម្រាប់គ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុ (Bank & FIs) និងប្រតិបត្តិករទឹកឯកជន (PWOs) ដើម្បីជួបពិភាក្សា និងស្វែងរកដំណោះស្រាយពាក់ព័ន្ធលើការផ្តល់ និងទទួលបានឥណទាន។ ជាងនេះទៅទៀតសិក្ខាសាលានេះនឹងពិនិត្យមើលលទ្ធភាពផ្គូរផ្គងនូវតម្រូវការ និងលក្ខខណ្ឌ រវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ សិក្ខាសាលានេះមានការចូលរួមពីសំណាក់មន្ត្រីជាន់ខ្ពស់មកពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន ព្រមទាំងតំណាងមកពីសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ដែលសរុបមានអ្នកចូលរួមចំនួន ៣១ នាក់។



*រូបភាពទីៈ ៨ សិក្ខាសាលាស្តីអំពីការចាប់ផ្តើមកម្មវិធីឥណទានទឹកស្អាត នៅសណ្ឋាគារភ្នំពេញ*

### ៤.១.៥. ការសម្របសម្រួលកម្ចីរវាងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជន និងស្ថាប័នហិរញ្ញវត្ថុ

គម្រោងបានសម្របសម្រួលកម្ចីជូនប្រតិបត្តិករចំនួនប្រាំមួយស្ថានីយ។ ជាលទ្ធផលប្រតិបត្តិករទឹកស្អាតដឹកនាំដោយស្ត្រីចំនួន១ស្ថានីយ ទទួលបានកម្ចីពីធនាគារ SME ដែលមានទំហំទឹកប្រាក់ចំនួន ២០៥,០០០ ដុល្លារអាមេរិក ដើម្បី៖ ១) ពង្រីកបណ្តាញបំពង់ ២) ដំឡើងម៉ាស៊ីនបូមទឹកថ្មី ៣) កែលម្អអាងប្រព្រឹត្តិកម្ម និង៤) ដំឡើងប្រព័ន្ធថាមពលព្រះអាទិត្យ ៦០KVA។ ដោយផ្អែកលើគោលការណ៍ធនាគារ SME នឹងគិតអត្រាការប្រាក់ចំនួន ៥.៥% ក្នុងមួយឆ្នាំ និងដោយយោងលើអនុស្សរណៈយោគយល់គ្នា រវាងសមាគម CWA និងធនគារ SME ដូច្នេះខាងធនាគារ SME នឹងបញ្ចុះតម្លៃលើអត្រាការប្រាក់បន្ថែមចំនួន ០.២៥% ក្នុងមួយឆ្នាំជូនដល់ប្រតិបត្តិករជាស្ត្រីនេះបន្ថែមទៀត។




*រូបភាពទី៖ ៩ គម្រោងផ្តល់ប្រាក់កម្ចីដោយផ្ទាល់*

### ៤.១.៦. ទស្សនកិច្ចទៅប្រទេសឥណ្ឌូនេស៊ី

**ថ្ងៃទី២៥-២៩ ខែមិថុនា ឆ្នាំ២០២៣** ក្រោមការឧបត្ថម្ភរបស់អង្គការ Water.org សមាគមបានរៀបចំដំណើរទស្សនកិច្ចសិក្សាទៅកាន់ប្រទេសឥណ្ឌូនេស៊ី ដែលមានសមាសភាពចូលរួមពី អគ្គនាយកដ្ឋានទឹកស្អាត នៃក្រសួងឧរបន ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជននៅក្នុងគម្រោង បុគ្គលិកអង្គការ Water.org និងបុគ្គលិកសមាគម សរុបចំនួន ១៤នាក់(ស្រី២នាក់)។ ខាងក្រោមនេះជាលទ្ធផលនៃដំណើរទស្សនកិច្ចសិក្សា៖

- ❖ ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣៖ គណប្រតិភូពីប្រទេសកម្ពុជាបានចូលរួមក្នុងកិច្ចប្រជុំ ដើម្បីស្វែងយល់អំពី៖ ១). តួនាទីរបស់សមាគមផ្គត់ផ្គង់ទឹកជាតិឥណ្ឌូនេស៊ី PERPAMSI និងទិដ្ឋភាពទូទៅនៃការផ្គត់ផ្គង់ទឹកស្អាតក្នុងទីក្រុង (PDAMs) ២). ការណែនាំកម្មវិធី Water Equity ៣). ការចែករំលែកភាពជាដៃគូរវាងក្រុមហ៊ុន Grenex និងរដ្ឋាករផ្គត់ផ្គង់ទឹកស្អាត Bekasi ក្នុងការកាត់បន្ថយការបាត់បង់ទឹក។



*រូបភាពទី៖ ១០ ការថតរូបអនុស្សាវរីយ៍ក្រោយបញ្ចប់កិច្ចប្រជុំ*



*រូបភាពទី៖ ១១ ដំណើរទស្សនកិច្ចសិក្សា ទៅកាន់ប្រទេសឥណ្ឌូនេស៊ី*

២. ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៣៖ ចូលរួមក្នុងសិក្ខាសាលាចែករំលែកបទពិសោធន៍លើផ្នែកហិរញ្ញវត្ថុប្រើប្រាស់តាមរយៈធនាគារ និងបង្ហាញអំពីទស្សនៈរបស់ PDAM Sleman, PDAM Batang និង Bank Sleman។ គណប្រតិភូមកពីប្រទេសកម្ពុជាបានអញ្ជើញទស្សនាប្រាសាទ Borobudur ដែលជាប្រាសាទព្រះពុទ្ធសាសនាដែលត្រូវបានកសាងឡើងតាំងពីសតវត្សទី៨ នៃគ្រឹះសករាជ។



*រូបភាពទី៖ ១២ ដំណើរទស្សនកិច្ចសិក្សា ទៅកាន់ប្រទេសឥណ្ឌូនេស៊ី ការប្រគល់វិត្តអនុស្សាវរីយ៍*

៣. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣៖ ក្រុមការងារបានទៅទស្សនា អាងប្រព្រឹត្តិកម្មសម្អាតទឹក (WTP) ដែលគ្រប់គ្រងដោយក្រុមហ៊ុន Grenex នៅទីក្រុង Bakasi។



*រូបភាពទី៖ ១៣ ទស្សនា អាងប្រព្រឹត្តិកម្មសម្អាតទឹក (WTP) ដែលគ្រប់គ្រងដោយក្រុមហ៊ុន Grenex*

## ៤.២. គម្រោងសម្ព័ន្ធភាពដើម្បីអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌ (Aide et Action)

# # ក្រោមជំនួយឧបត្ថម្ភពីអង្គការ Aide et Action(AEA) សមាគមបាននឹងកំពុងអនុវត្តគម្រោង « សម្ព័ន្ធភាពដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការគាំទ្រសំឡេងដើម្បីសមធម៌សង្គម (CO-SAVED)» ក្នុងខេត្តគោលដៅចំនួនបួន (ខេត្តកែប ខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកោះកុង)។

### ៤.២.១. កិច្ចប្រជុំជ្រើសរើសឃុំ

សមាគមបានរៀបចំកិច្ចប្រជុំស្តីពី«ការជ្រើសរើសឃុំគោលដៅ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត» នៅការិយាល័យសមាគម។ អង្គប្រជុំបានកំណត់យកតំបន់គោលដៅនៅស្រុកកំពង់សីលា ខេត្តព្រះសីហនុ និងស្រុកកំពង់ត្រាច ខេត្តកំពត។ ចំនួនអ្នកចូលរួមសរុប ១២នាក់(ស្រី៦នាក់) មកពីស្ថានីយផ្គត់ផ្គត់ទឹកស្អាតកំពង់សីលា១នាក់ ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ភ្នំមាស ១នាក់ អង្គការ AEA ៥នាក់ និងបុគ្គលិកសមាគម ៥នាក់។



*រូបភាពទី១៤៖ ការជ្រើសរើសឃុំគោលដៅ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត*

### ៤.២.១. ការដេញថ្លៃទុយោ

ក្នុងត្រីមាសទី២នេះ សមាគមបានផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពី«ការដេញថ្លៃក្នុងការផ្គត់ផ្គង់បំពង់ទឹកស្អាត» នៅលើគេហទំព័រសមាគម ក៏ដូចជាប្រព័ន្ធទំនាក់ទំនងសង្គម។ ជាលទ្ធផលមាន



*រូបភាពទី១៥៖ ការដេញថ្លៃក្នុងការផ្គត់ផ្គង់បំពង់ទឹកស្អាត នៅការិយាល័យសមាគម*

ក្រុមហ៊ុនចំនួន ៩ បានដាក់ពាក្យដេញថ្លៃក្នុងការផ្គត់ផ្គង់បំពង់ទឹកស្អាតទៅដល់ស្ថានីយ ២គឺស្ថានីយផ្គត់ផ្គង់ទឹកស្អាតភ្នំមាស និងស្ថានីយផ្គត់ផ្គង់ទឹកស្អាតកំពង់សីលា ដែលទទួលបានការវិនិយោគពីគម្រោង។

នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៣ សមាគមបានបើកកញ្ចប់ការដេញថ្លៃផ្គត់ផ្គង់បំពង់ទឹកស្អាតដល់ប្រតិបត្តិករទាំងពីរខាងលើ។ ជាលទ្ធផល ក្រុមហ៊ុន ធី ស៊ី យូ ប៉ូលី អេធើប្រាយ (T.C.U Polys Enterprise)ជាអ្នកទទួលការផ្គត់ផ្គង់បំពង់ទឹកស្អាត។

### ៤.២.៣. វគ្គបណ្តុះបណ្តាល

នៅក្នុងត្រីមាសទី២នេះ សមាគមបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពី«តួនាទី និងការទទួលខុសត្រូវលើសេវាកម្មផ្គត់ផ្គង់ទឹកស្អាត» និង «បច្ចេកទេសថែទាំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត និងស្តង់ដាគុណភាពទឹកស្អាត» ជូនដល់អាជ្ញាធរ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត នៅស្រុកកំពង់ត្រាច ខេត្តកំពត។ វគ្គបណ្តុះបណ្តាលមានបំណងឱ្យអាជ្ញាធរ និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត ចូលរួមតាមដានសេវាកម្ម និងគុណភាពទឹកស្អាត និងជំរុញឱ្យមានទំនួលខុសត្រូវខ្ពស់របស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតឯកជនចំពោះអតិថិជន និងអាជ្ញាធរមូលដ្ឋាន។ ដូចគ្នាដែរអាជ្ញាធរមូលដ្ឋានចូលរួមសហការ និងគាំទ្រដល់ប្រតិបត្តិករផ្គង់ផ្គង់ទឹកស្អាតក្នុងការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋ។

នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលអ្នកចូលរួមនឹងមានលទ្ធភាព៖

1. រៀបរាប់បានពីតួនាទី និងការទទួលខុសត្រូវរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត អាជ្ញាធរមូលដ្ឋាន និងសហគមន៍
2. ឆ្លុះបញ្ចាំងអំពីការអនុវត្តតួនាទីរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត អាជ្ញាធរមូលដ្ឋាន និងសហគមន៍
3. កំណត់ផែនការដាក់លាក់ដើម្បីអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត
4. ពន្យល់បានអំពីដំណើរការនៃការសម្អាតទឹកចាប់ពីប្រភពទឹករហូតដល់អ្នកប្រើប្រាស់
5. ពន្យល់បានពីមូលដ្ឋាននៃដំណើរការប្រតិបត្តិ និងការថែទាំប្រព័ន្ធសម្អាតទឹក
6. រៀបរាប់បានអំពីប៉ារ៉ាម៉ែត្រសំខាន់ៗនៃស្តង់ដាគុណភាពទឹកស្អាតថ្នាក់ជាតិ និងអនុវត្តការតេស្តទឹកលើប៉ារ៉ាម៉ែត្រប្រចាំថ្ងៃតាមឧបករណ៍សាមញ្ញ។




*រូបភាពទី១៦៖ តួនាទី និងការទទួលខុសត្រូវលើសេវាកម្មផ្គត់ផ្គង់ទឹកស្អាត*

## ៤.៣. គម្រោងសហគមន៍ដឹកនាំទឹកស្អាត និងអនាម័យធន់នឹងអាកាសធាតុ ប្រកបដោយបរិយាប័ន្ន (EMW)

នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៣ ក្រោមការឧបត្ថម្ភធនអង្គការ EMW បុគ្គលិកសមាគមបានចូលរួមក្នុងការសាកល្បងប្រើប្រាស់សម្ភារៈផ្សព្វផ្សាយគម្រោង (CLICR-WASH) និងការទទួលបានព័ត៌មានត្រឡប់ ការផ្សព្វផ្សាយនេះធ្វើឡើងចំនួន ២លើក៖

១- នៅភូមិពុទ្ធវង្ស ឃុំថ្កូវ ស្រុកកំពង់ត្របែក (វគ្គពេលព្រឹក) - ជាឃុំដែលគ្មានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត អ្នកចូលរួមជាសហគមន៍ចំនួន ២៦នាក់ (ស្ត្រី កុមារី និងបុរស)

២- នៅភូមិស្វាយទាប ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល (វគ្គពេលរសៀល) - ឃុំដែលមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត អ្នកចូលរួមជាសហគមន៍ចំនួន ២៨នាក់ (ស្ត្រី កុមារី និងបុរស)



*រូបភាពទី១៧៖ ការផ្សព្វផ្សាយការសាកល្បងប្រើប្រាស់សម្ភារៈជូនដល់សហគមន៍*

## ៥. ទស្សនកិច្ចសិក្សាក្រៅប្រទេស

ក្នុងត្រីមាសទី២នេះ សមាគមបានរៀបចំទស្សនកិច្ចសិក្សាក្រៅប្រទេសចំនួន ១លើកក្រោមកិច្ចសហការរបស់របស់សមាគមទឹកស្ត្រាលី (AWA)៖

- **ថ្ងៃទី០៩-១៣ ខែឧសភា ឆ្នាំ២០២៣** សមាគមបានចូលរួមសន្និសីទ និងពិព័រណ៌ទឹកអូស្ត្រាលី (Ozwater'23) នៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី ជាមួយគណៈប្រតិភូកម្ពុជារួមមាន៖ តំណាងក្រសួងឧស្សាហកម្ម... 



*រូបភាពទី១៨ និងទី១៩៖ សន្និសីទ និងពិព័រណ៌ទឹកអូស្ត្រាលី (Ozwater'23) នៅទីក្រុងស៊ីដនី ប្រទេសអូស្ត្រាលី*



- **ពីថ្ងៃទី០៦-០៨ ខែមិថុនា ឆ្នាំ២០២៣** សមាគមបានចូលរួមក្នុងវេទិកាស្តីពី«ទឹកស្អាត និងទឹកកខ្វក់នៅក្នុងប្រទេសឥណ្ឌូនេស៊ី» និងការដាក់តាំងពិព័រណ៍ ដើម្បីសិក្សារៀនសូត្រពីចំណេះដឹងថ្មីៗ និងចែករំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមករវាងសិក្ខាកាមដែលអញ្ជើញមកពី ៧ប្រទេស រួមមាន៖ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ថៃ ហ្វីលីពីន កម្ពុជា វៀតណាម និងឡាវ។ គោលបំណង នៃការរៀបចំ វេទិកា និងការដាក់តាំងពិព័រណ៍នេះគឺដើម្បីបង្ហាញពីការស្តារភាពល្បីល្បាញរបស់បណ្តាញការប្រើប្រាស់ទឹកនៅអាស៊ីអាគ្នេយ៍ (SEAWUN) ដល់សមាគមទឹកស្អាតផ្សេងៗទៀតនៅក្នុងប្រទេសអាស៊ីអាគ្នេយ៍។ ទន្ទឹមនេះដែរតំណាងសមាគមទឹកស្អាតដែលអញ្ជើញមកពីប្រទេសអាស៊ីអាគ្នេយ៍ បានធ្វើទស្សនៈកិច្ចសិក្សាទៅកាន់ រោងចក្រប្រព្រឹត្តកម្មទឹកស្អាតឪកេង នៅក្នុងទី BOKUR ខេត្តចាវ៉ាខាងលិច។



*រូបភាពទី២០៖ វេទិកា និង ការដាក់តាំងពិព័រណ៍ទឹកស្អាត និងទឹកកខ្វក់ នៅប្រទេសឥណ្ឌូនេស៊ី*